# គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

## រួមគិត រួមធ្វើ រួមទទួលខុសត្រូវ

# ក្រមងគំនិត

www.camldp.org

# អារម្ភកថា

"ពន្យល់ ពន្យល់ ពន្យល់ ... ពន្យល់" លើគោលធំៗទាំងបី ៖ កិច្ចប្រតិបត្តិព្រះធម៌ សីលធម៌សង្គម និងប្រជាធិបតេយ្យ/នយោបាយ គឺជាចំណុចចាប់ផ្តើមនៃសកម្មភាពនយោបាយរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ ដូច្នេះ កូនសៀវភៅសម្រង់គំនិតនេះត្រូវបានចងក្រងដោយផ្អែកដោយផ្ទាល់ ឬប្រយោលលើខ្លឹមសារសំឡេងជាងពីរពាន់ម៉ោងរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ ពិតណាស់ កម្រងគំនិតនេះគ្រាន់តែជាចំនួនតូចមួយប៉ុណ្ណោះ អាស្រ័យហេតុនេះ ក្រុមព័ត៌មានបន្តព្យាយាមស្រង់គំនិតផ្សេងៗ និងបោះពុម្ពផ្សាយជាបន្តបន្ទាប់។

រាល់គំនិតទាំងអស់នៅក្នុងសៀវភៅនេះពុំមានការរឹតត្បិតក្នុងការថតចម្លង ផ្សព្វផ្សាយបន្តទេ ពោលគឺមិត្តអ្នកអានអាចចំលងប្រើប្រាស់ ដោយពុំចាំបាច់មានការអនុញ្ញាតពីក្រុមការងារយើងឡើយ។

គោលបំណងធំនៃកិច្ចការរៀបរៀងនេះ នឹងបានសម្រេចដូចប្រាថ្នា ប្រសិនបើការបោះពុម្ពផ្សាយ

សៀវភៅ "កម្រងគំនិត"នេះ អាចជួយជំរុញទឹកចិត្ត ឲ្យមានការត្រិះរិះពិចារណាអំពីប្រជាធិបតេយ្យ/ នយោបាយ កិច្ចប្រតិបត្តិព្រះធម៌ និងសីលធម៌សង្គម ដែលអាចជួយផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋខ្មែរពីទម្លាប់ចាស់។

យើងយល់ឃើញថា គំនិត មតិ ទស្សនៈ ឬមនោគមវិជ្ជាខ្លះ អាចលំបាកយល់ ឬងាយនឹងភ័ន្តច្រលំ ជាពិសេសអ្នកអានដែលជាមនុស្សមិនស្គាល់ ឬធ្លាប់ស្តាប់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ ដូច្នេះ ដើម្បីយល់ច្បាស់ សូមលោក លោកស្រីស្វែងយល់បន្ថែមដោយការដាវឡូតសំឡេងពីស្នាក់ការកណ្តាល/ សាខាបក្សតាមខេត្តក្រុង/អ្នកស្ម័គ្រចិត្ត ឬតាមគេហទំព័រ www.camldp.org បណ្តាញសង្គម Youtube ឬកម្មវិធី Paltalk: Koun Khmer Room។

**រួមគិត រួមធ្វើ រួមទទួលខុសត្រូវ!**

ក្រុមព័ត៌មាន គ.ស.ប

ពួកយើងប្រញាប់
ខ្លាំងណាស់ ដូច្នេះយើងត្រូវដើរយឺតៗ
មួយជំហានៗ យើងឈានចូលសង្គមត្រូវ
ប្រយត្ន័បំផុត។ យើងគ្មានពេលធ្វើសាក
ឬធ្វើ ជាលើកទី២ឡើយ។

គោលដៅរួមរបស់
ពួកយើងគឺ"មាតុភូមិមួយដែល
ពួកយើងរស់នៅដោយស្មើភាពគ្នាក្នុង
ភាពជាម្ចាស់"។
គោលដៅយើងនៅឆ្ងាយ
តែជាគោលដៅដែលយើងមាន
ទំនុកចិត្តថាយើងអាចទៅដល់បាន។

យើងសង្ឃឹមថាយើងអាចនឹងទៅដល់
គោលដៅព្រោះអ្វីដែលយើងធ្វើ
(ការដាក់យន្តការ៨ចំណុច) ក្នុងប្រព័ន្ធ
ដឹកនាំរដ្ឋជាផលប្រយោជន៍រួមរបស់
ប្រជាពលរដ្ឋទូទៅ។

នយោបាយគឺជាសិល្បៈធ្វើឲ្យបាន
សម្រេចគោលដៅ ឬជា
សិល្បៈនៃការដោះស្រាយបញ្ហា។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ កើតពី
ប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បី
ប្រជាពលរដ្ឋ។ ទាំងអស់គ្នា
ដើម្បីទាំងអស់គ្នា!

តុល្យភាពអំណាចគឺជា
តុល្យភាពកំលាំងរវាងប្រជាពលរដ្ឋ និងតំណាង
ដែលយើងបានរើស។ មានន័យថា យើងអាចរើស
និងអាចទម្លាក់តំណាងបាន។ ដើម្បីទម្លាក់បាន
លុះណាយើងកាត់បន្ថយអំណាចរបស់
តំណាងនោះរួចហើយ។

រដ្ឋាភិបាលនៅ
ក្នុងសង្គមប្រជាធិបតេយ្យ
គឺជារដ្ឋាភិបាលដែលកើតឡើង
ដោយប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ
និងដើម្បីប្រជាពលរដ្ឋ។

នៅក្នុងសង្គមប្រជាធិបតេយ្យ
ការដឹកនាំប្រៀបបានទៅនឹងការ
បររទេះសេះ។ រដ្ឋាភិបាលជារទេះ
ហើយប្រជាពលរដ្ឋជាអ្នកបររទេះនោះ។

នៅក្នុងសង្គមប្រជាធិបតេយ្យ គ្មាននរណា
ធ្វើការសម្រាប់នរណាម្នាក់ទៀតឡើយ។
មនុស្សទាំងអស់គ្នាធ្វើការដើម្បី
ប្រយោជន៍ទាំងអស់គ្នា។

នៅក្នុងសង្គមប្រជាធិបតេយ្យគ្មានទេ
វណ្ណៈដឹកនាំគេ និងវណ្ណៈដែល
ត្រូវបានគេដឹកនាំ គឺ
ទាំងអស់គ្នា ដើម្បី
ទាំងអស់គ្នា។

យើងបង្កើតបក្សដើម្បីជាតិ មិនមែន
ជាតិដើម្បីបក្សនោះទេ។ យើងខិតខំ
គ្រប់បែបយ៉ាងដើម្បីជួយជាតិ វាផ្ទុយពី
ខិតខំគ្រប់បែបយ៉ាងដើម្បីបំផ្លាញជាតិធ្វើ
ឲ្យតែបានប្រយោជន៍ខ្លួន ឬបក្ខពួកខ្លួន។

ប្រជាធិបតេយ្យគឺ
គេនិយាយតែពីរបៀបដឹកនាំរដ្ឋ
ដោយប្រជាពលរដ្ឋប៉ុណ្ណោះ រីឯការរីកចំរើន
ឬមិនរីកចម្រើនគឺមកពីប្រជាពលរដ្ឋ
នៅក្នុងសង្គមនោះឯង។

សូមអ្នកកុំយកផ្ទាំងបាយមកលាយឡំជាមួយ
កិច្ចការនយោបាយ។ កិច្ចការនយោបាយ
គឺជាកិច្ចការដើម្បីជួយដល់សង្គមជាតិ
អ្នកឲ្យរីកចម្រើន ទាំងផ្នែកលោក
សម្ភារៈ ទាំងផ្នែក
មនោសញ្ចេតនា។

គណបក្សប្រជាធិបតេយ្យគឺ កើតពីប្រជា
ពលរដ្ឋ របស់ប្រជាពលរដ្ឋ និងដើម្បី
ប្រជាពលរដ្ឋ គឺលុះណាមានការ
ចូលរួមដោយការយល់ដឹង ធ្វើ
ប្រព័ន្ធពីប្រជាពលរដ្ឋ។

ប្រព័ន្ធប្រជាធិបតេយ្យអាច
ដំណើរការបាន លុះត្រាតែ
មានតុល្យភាពអំណាចរវាងអ្នកដឹកនាំ
និងប្រជាពលរដ្ឋ។

ដើម្បីផ្លាស់ប្តូរសង្គមទាំងមូល គឺយើងត្រូវផ្លាស់ប្តូរ
មនុស្សក្នុងសង្គម ហើយដើម្បីផ្លាស់ប្តូរមនុស្ស
ក្នុងសង្គមនោះ គឺជាដំបូងយើងត្រូវផ្លាស់ប្តូរ
ការគិតរបស់គេជាមុនសិន។

អ្នកនៅស្ងៀមមិនចូលរួមកសាងសង្គម
ឲ្យមានការរីកចំរើន មានន័យថា
អ្នកបានចូលរួមបំផ្លាញ
សង្គមអ្នកហើយ។

អ្នកឈរមើលអ្នកផ្សេងប្រព្រឹត្តអំពើអាក្រក់មាន
ន័យថា  អ្នកក៏ជាអ្នករួមចំណែកបង្កើតអំពើ
អាក្រក់ដែរ។

កាលណាយើងមានគុណសម្បត្តិរបស់ចិត្ត
គ្រប់គ្រាន់ មានន័យថា ចិត្តយើងស្អាត
(គ្មានលោភៈ គ្មានទោសៈ គ្មានមោហៈ)
យើងអាច
ប្រើប្រតិកម្មផ្លូវចិត្តដើម្បី
ដោះស្រាយបញ្ហា និងប្រើប្រតិកម្ម
ផ្លូវចិត្តឆ្លើយតបទៅអ្នកដទៃយ៉ាងឆាប់រហ័ស
និងល្អបំផុតហើយវាត្រឹមត្រូវ ព្រោះចិត្តយើង
មានគុណសម្បត្តិរួចហើយ។

សម្តីសជាតិមាយាទសពូជ។ សម្តីខ្ញុំ មាយាទខ្ញុំ
បង្ហាញថា ខ្ញុំតាមវាយអំពើអាក្រក់មិនដកដៃ
មិនសំចៃមាត់ មិនបន្ទាយពេលវេលា
មិនឈប់ឈរ។

ការងារដែលផ្តើមចេញតែពីប្រយោជន៍ផ្ទាល់ខ្លួន
មិនឆ្លើយតបជាមួយសេចក្តី
ត្រូវការរបស់មនុស្សឡើយ។ ការងារដែល
ផ្តើមពីបេះដូងសង្គ្រោះ គឺចេញ
ពីបេះដូង មិនមែនចេញពីខួរ
ក្បាលនោះទេ។ ចូរអ្នកសួរ
បេះដូងអ្នកឲ្យបានច្បាស់
ថា អ្នកពិតជាមាន
បេះដូងសង្គ្រោះ
ពិត ឬយ៉ាងណា?

យើងគួរតែបំព្រួញទំនាស់ដោយពង្រីកការ
ចរចា ឬដំណោះស្រាយដោយផ្អែកលើ
បាតគ្រឹះសុចរិត និងយុត្តិធម៌។

មនុស្សអាក្រក់មានធាតុអាក្រក់ ជាធាតុ
ទ្រទ្រង់ រីឯមនុស្សល្អមានធាតុល្អជា
ធាតុទ្រទ្រង់ មិនខុសគ្នានឹងអំពិល
មានជាតិជូរជាធាតុទ្រទ្រង់ ឯ
អំពៅមានជាតិផ្អែមជា
ធាតុទ្រទ្រង់។

មនុស្សល្អមានធាតុសំខាន់ប្រាំយ៉ាងគឺ
(១) ស្គាល់អំពើល្អ
(២) ដាំបណ្តុះអំពើល្អដាក់ក្នុងខ្លួន
(៣) ប្រតិបត្តិអំពើល្អ
(៤) ពង្រីកអំពើល្អ និង
(៥) ការពារអំពើល្អ។

កុំធ្វើជាទីផ្គាប់ចិត្តរបស់បុគ្គលពាល។ ពាលគឺ
ផ្ទុយពីសប្បុរស។ សប្បុរសស្គាល់ហេតុនៃ
សេចក្តីវិនាស និងហេតុនៃសេចក្តី
ចម្រើន។ ដឹងហេតុនៃសេចក្តីវិនាស
ទម្លាក់ចុះ ងាកមកចាប់យក
ហេតុនៃសេចក្តីចម្រើន។

ក្នុងចលនាមួយណាក៏ដោយ ការចូលរួមដោយ
សទ្ធាជ្រះថ្លា គឺជ្រះស្រលះ គ្មានមន្ទិលសង្ស័យ
នៅក្នុងផ្លូវចិត្ត វាជាការចាំបាច់បំផុតដែល
នាំដល់សាមគ្គីភាពក្នុងក្រុម និង
សង្គមជាតិទាំងមូល ដើម្បី
ឲ្យមានការចូលរួម ទាំង
កំលាំងកាយ ចរិកា និង
បញ្ញាដោយការ
ពេញចិត្ត។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ថ្វីត្បិតតែ
មានអ្នកគាំទ្រតិចនៅឡើយ ប៉ុន្តែនេះជាពន្លក
នៃក្តីសង្ឃឹមថ្មីរបស់ប្រជាពលរដ្ឋ ដូច្នេះ
ការងារគ្រប់បែបយ៉ាង គឺត្រូវមាន
ការប្រុងប្រយ័ត្នបំផុត ជាពិសេស
ការកសាងចលនាស្នូល
របស់បក្ស។

ការងារមិនច្របូកច្របល់គឺជា
មង្គលដ៏ប្រសើរ ហើយការងារមិនច្របូក
ច្របល់ទៅបានលុះណា ខួរក្បាលរបស់បុគ្គល
នោះមិនច្របូកច្របល់ដោយផ្តើមពីការយល់
ត្រូវនាំមកនូវការគិតត្រូវ និងទង្វើត្រូវ។

យើងមិនមែនអ្នកខ្លាំងទេ ប៉ុន្តែយើងចេះធ្វើឲ្យ
អ្នកចូលរួមជាមួយយើងមានជំហររឹងមាំ និង
ខ្លាំងក្លាដែរ។

កាតព្វកិច្ចមួយដែលមិនអាចខ្វះបានរបស់
មនុស្សល្អគឺការតាមវាយកម្ទេចអំពើ
អាក្រក់មិនឈប់។

អ្នកល្បីល្បាញលើលោកភាគច្រើនសុទ្ធសឹងតែ
មនុស្សធ្វើប្រយោជន៍ដើម្បីអ្នកដទៃ ហើយ
ប្រាសចាកភាពអាត្មានិយម ហើយចាត់
ទុកខ្លួនឯងដូចលាមក គ្មានតម្លៃអ្វី
ទាំងអស់បើគ្មានការងារជា
ឧត្តមគតិសម្រាប់ធ្វើ។

គោលនយោបាយរបស់
គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺ
បង្ហាញពីទឹកចិត្ត និងទស្សនវិស័យ
(យើងក៏អាចធ្វើបាន ហើយអ្នក
ដទៃក៏អាចយកទៅធ្វើបាន)
ក្នុងការដោះស្រាយបញ្ហា
ដែលគណបក្សណាក៏
អាចយកទៅធ្វើបាន
ឲ្យតែគេយល់
ច្បាស់។

ដើម្បីជួយមនុស្សទាំងអស់ក្នុងសង្គម
ដើម្បីដោះស្រាយបញ្ហាគ្រប់បែបយ៉ាងក្រៅពី
ធ្វើនយោបាយ ដោយដួងចិត្តសង្គ្រោះ និង
ទស្សនវិស័យភ្លឺថ្លា តើយើងត្រូវធ្វើតាម
មធ្យោបាយអ្វីទៅវិញ?

ការងារថ្លៃថ្នូរគឺ
ការងារប្រាសចាកភាព
អាត្មានិយម។ អាត្មានិយមគឺការ
គិតតែពីខ្លួនឯងដែលមិនខ្វល់ពីអ្នកដទៃ។

គ្មានមនុស្សណាថោកទាបជាង
មនុស្សដែលទទួលថា ខ្លួនថោកទាប
ដើម្បីបន្តសកម្មភាពថោកទាបរបស់ខ្លួនឡើយ។

បើទិទៀនសូមមកជាមួយហេតុផល និងសុចរិត
ភាពស្មោះត្រង់ក្នុងនាមជាមនុស្សជាតិដូចគ្នា។

ជាងគម្ពីរ ជាងគេជាគ្រូ ជាងហ្វូង គឺហេតុផល។
បើយើងពិចារណាទៅឃើញថា គ្មានហេតុផល
យើងមិនទទួលយកឡើយ។

បើខ្មែរភាគច្រើនចាត់ទុកប្រទេសខ្លួនឯងជាផ្ទះ
របស់ពួកគេច្បាស់ជាពួកគេនាំគ្នាការពារយ៉ាង
សស្រាក់សស្រាំមិនខាន។

បាតគ្រឹះរបស់ក្រុមយើង(គណបក្សសម្ព័ន្ធដើម្បី
ប្រជាធិបតេយ្យ) គឺសុចរិត យើងនិយាយតែ
ការពិត។ អ្វីៗដែលយើងយល់ថាត្រឹម
ត្រូវ ហើយដល់កាលគឺពួកយើង
និយាយដោយទទួលខុសត្រូវ
រាល់ពាក្យសម្ដីដែលយើង
បានទម្លាក់ទៅ
ក្នុងសង្គម។

ចំណុចគន្លឹះដែលក្រុមយើងដើរគ្រប់ទីកន្លែង ពន្យល់ប្រជាពលរដ្ឋគឺចង់ឲ្យប្រជាពលរដ្ឋយល់ពី ៖

១. ផលវិបាកដែលកើតពីអំណាចប្រមូលផ្តុំ
២. ផលប្រយោជន៍ដែលកើតពីការបំបែកអំណាចរដ្ឋ ឬបំបែកការទទួលខុសត្រូវ។ យើងធ្វើដូចនេះព្រោះអាណិតខ្មែរទាំងអស់ដែលបាន និងកំពុងរងទុក្ខវេទនាគ្រប់បែបយ៉ាងដោយចិត្តមេត្តា ចិត្តករុណាប្រកបដោយភាពសុចរិតស្អាតស្អំ។

ការគាំទ្រគណបក្ស
វាមិនមែនជារឿងខុសនោះ
ទេ តែដែលខុសនោះគឺត្រង់យើងដឹងថា
គណបក្សនោះមិនល្អហើយយើងនៅតែគាំទ្រ
ព្រោះទទួលបានប្រយោជន៍តិចតួចហ៊ាន
បំផ្លាញប្រយោជន៍ជាតិ។

បញ្ហាសំខាន់បំផុតនៅក្នុងប្រទេសខ្មែរគឺ
បណ្ដាលមកពីភាពល្ងង់ខ្លៅ និងភាព
អសកម្មក្នុងការចូលរួមកសាង
ប្រទេសជាតិរបស់ប្រជា
ពលរដ្ឋភាគច្រើន។

គណបក្សនយោបាយមួយអាចដឹកនាំប្រទេស
រីកចម្រើន និងអភិវឌ្ឍន៍ទៅបានលុះណា ៖

១. មានគោលនយោបាយច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាប្រទេសជាតិគ្រប់បែបយ៉ាង។
២. ធនធានមនុស្សក្នុងការអនុវត្តគោលនយោបាយដែលក្រុមខ្លួនបានកំណត់។ យល់ដឹងពីមនោគមវិជ្ជា និងស្មោះស្ម័គ្រនឹងមនោគមវិជ្ជាដែលខ្លួនយល់ និងស្រលាញ់។

# ការវិវឌ្ឍរបស់ប្រទេសមួយខុសពីប្រទេសមួយ ផ្សេងទៀតគឺវាទាក់ទងទៅនឹងការគិតរបស់ ប្រជាពលរដ្ឋនៅក្នុងប្រទេសនោះឯង។



ការជួយប្រជាពលរដ្ឋពិតប្រាកដគឺការជួយ
ប្រជាពលរដ្ឋឲ្យចេះជួយខ្លួនឯង មិនមែនធ្វើជា
មនុស្សខ្លាំងឲ្យប្រជាពលរដ្ឋពឹងនោះទេ។

របៀបធ្វើការរបស់ពួកយើង
គឺតួនាទីរត់រកមនុស្ស មិនមែន
មនុស្សរត់រកតួនាទីឡើយ មានន័យថា
យើងធ្វើការដោយមិនគិតទៅរកតំណែង។

ក្នុងធម្មជាតិនេះគ្មានអ្វីដែលមិនសមនោះទេ តែ
ពេលខ្លះអ្នកមានអារម្មណ៍ថាមិនសម គឺ
ព្រោះតែអ្នកមិនទាន់យល់អំពីដំណើរនៃធម្មជាតិ។

សូមឲ្យ
សកម្មភាពការងាររបស់អ្នកទៅ
មុនពាក្យសម្ដី សូមកុំសន្យាគ្រប់បែបយ៉ាង
តែធ្វើមិនកើតដូចពាក្យមួយឃ្លា
ពោលថា
"ទ្រឹស្ដីហៀរដល់កែង អនុវត្តន៍ជាក់ស្ដែងសូន្យ"។

នៅលើលោកនេះមានតែអ្វីដែលគេមិនទាន់ដឹង
តែគ្មានអ្វីដែលគេមិនអាចដឹងនោះទេ។

បេះដូងអ្នកប្រាជ្ញចិញ្ចាចចាំងលោកិយ រស់គ្មាន
ចង់បានអ្វីក្នុងលោកា តែត្រូវពាលខ្លៅប្រៀប
លោកទៅបន្លា វាខំកាប់ឆ្ការឲ្យលោកា
ងងឹតសូន្យឈឹង។

សរសើរបុគ្គលដែលគួរសរសើរ និន្ទាបុគ្គល
ដែលគួរនិន្ទារមែងឡើងឋានសួគ៌ដូចគេចាប់ដាក់
ផ្ទុយទៅវិញ
សរសើរបុគ្គលដែលមិនគួរសរសើរ និងនិន្ទា
បុគ្គលដែលគួរសរសើររមែងធ្លាក់នរក
ដូចគេចាប់ដាក់។

ដឹងពីខ្លួនយើង ដឹងពីសត្រូវ ច្បាំងមួយរយដង
ឈ្នះមួយរយដង
មិនដឹងពីខ្លួនយើង ដឹងតែពីសត្រូវ ចាញ់
និងឈ្នះស្មើគ្នា
មិនដឹងពីខ្លួនយើង មិនដឹងពីសត្រូវ
ច្បាំងមួយរយដង ចាញ់ទាំងមួយរយដង។

ប្រយោជន៍ផ្ទាល់ខ្លួនគឺជាប្រយោជន៍អាស្រ័យ រី
ឯប្រយោជន៍រួមវិញគឺជាប្រយោជន៍ដើម
ប្រៀបបាននឹងដើមស្វាយបើគ្មានដើមក៏គ្មាន
ផ្លែដែរ។

ត្រីដែលគិតតែពីចំណី មិនគិតអំពីទឹក ថ្ងៃណា
មួយវានឹងត្រូវស្លាប់ទាំងអស់។

បុគ្គលដែលពូកែ
គេមិនខ្វល់ថានរណាជា
អ្នកធ្វើឲ្យទីនេះងងឹតនោះទេ តែគេ
ត្រូវគិតធ្វើយ៉ាងម៉េចដើម្បីឲ្យទីនោះភ្លឺវិញបាន។

អ្នកដទៃមើលងាយអ្នកបានគឺមកពីខ្លួនអ្នកធ្វើ
ឲ្យគេមើលងាយបាន មានន័យថាមកពីយើង
វាអត់ថ្លៃល្មមឲ្យគេមើលងាយបាន។

អ្នកដែលបំផ្លាញការគិតរបស់ប្រជាពលរដ្ឋគឺ
ស្មើនឹងការបំផ្លាញជាតិ ហើយថែមទាំង
បំផ្លាញដល់ឫសគល់ទៀតផង។

មនុស្សដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួនគឺកំពុង
បំផ្លាញប្រយោជន៍ផ្ទាល់ខ្លួនផង
និងប្រយោជន៍របស់ដទៃផង។

មនុស្សទាំងឡាយដែល
ព្រមជឿគឺព្រមបញ្ចប់ចំណេះដឹងរបស់ខ្លួន។

មនុស្សអាក្រក់ និង
មនុស្សល្អ កើតមាននៅលើលោក
នេះតាមច្បាប់ធម្មជាតិ។ ប៉ុន្តែមនុស្ស
អាក្រក់មានច្រើនគឺដោយសារភាព
អសកម្មនៃមនុស្សល្អ មិន
ដេញវាយអំពើ
អាក្រក់។

ទំនាស់មួយអាចដោះស្រាយបានយ៉ាងងាយ
ប្រសិនបើភាគីទំនាស់យកប្រយោជន៍រួម
ជាគោល។

ទំនាស់មួយមិនអាចដោះស្រាយបានឡើយ
ប្រសិនភាគីនៃទំនាស់តម្កល់ប្រយោជន៍
បុគ្គលជាធំ ឬឈរលើភាព
អាត្មានិយម។

អ្នកនយោបាយដែលមានបេះដូងសង្គ្រោះ
អាចជួយមនុស្សបានច្រើនបំផុត។

រឿងជឿ ឬមិនជឿគឺជារឿងសាសនា
ជារឿងអាត្មានិយមបំផុត។

ដំណើរជួយអ្នកដទៃដោយមិនរំពឹងផលត្រឡប់
មកវិញ នោះគឺជាដំណើរជួយខ្លួនឯងពិតៗ។

មនុស្សដែលមានគុណធម៌ខ្ពស់គឺជាមនុស្ស
ដែលប្រព្រឹត្តយ៉ាងហ្នឹងចំពោះលោកធម៌ទាំង៨។

ក្នុងវិធីសាស្ត្រផ្សព្វផ្សាយព្រះធម៌ ព្រះពុទ្ធប្រើ
ប្រាស់វិធីសាស្ត្រ "ប៥" ប្រាប់-បង្ហាញ
-បង្រៀន-បង្ហាត់-ប្រតិបត្តិ
អមដោយការពន្យល់
ក្បោះក្បាយក្នុង
បំណងឲ្យមនុស្សផ្លាស់
ប្តូរអត្តចរិក ឬផ្លាស់ប្តូរផ្នត់គំនិត
ផ្សេងៗហើយ ធ្វើឲ្យមនុស្សមានសទ្ធា និង
បង្រៀនឲ្យមនុស្សចេះជួយខ្លួនឯង
ដោយតថាគតមិនអាច
ជួយអ្នកបានឡើយ។

មនុស្សខុសពីសត្វ
ត្រង់កន្លែងចេះផ្តល់ហេតុ
ផល។ ដូចនេះ អ្នកនិយាយត្រូវផ្តល់
ហេតុផល ហើយអ្នកស្តាប់
ត្រូវចេះរកហេតុផល។

ប្រទេសមួយជឿនលឿនគឺជាប្រទេសដែល
ពលរដ្ឋមានវិន័យ ការប្តេជ្ញា សេចក្តី
អធិដ្ឋាន មនោសញ្ចេតនា
ការយល់ដឹងខ្ពស់។

អ្នកដឹកនាំត្រូវចេះធ្វើឲ្យសម្រេចគោលដៅដោយ
មិននាំឲ្យខូចប្រយោជន៍របស់អ្នកចូលរួម ។

បើអ្នកគ្មានសេចក្តីស្រម៉ៃទេ តើធ្វើដូចម្តេចទើប
អ្នកអាចធ្វើឲ្យសុបិននោះក្លាយជាការពិតបាន ?

# ដើម្បីមាតុភូមិមួយដែលពួកយើងរស់នៅ ដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់




# បំបែកប្រព័ន្ធដឹកនាំ ដែលប្រមូលផ្តុំអំណាច

តាមរយៈយន្តការ 8 ចំណុច

កាលណាមនុស្សម្នាក់កាន់តែជឿ មនុស្សនោះ
កាន់តែបិទការគិតរបស់ខ្លួន។

អ្នកដឹកនាំ
ត្រូវមានទេពកោសល្យ
ធម្មជាតិពីរយ៉ាងមិនអាចខ្វះបាន
គឺបេះដូងស្មោះត្រង់ពិតប្រាកដ និងមាន
ទស្សនវិស័យភ្លឺថ្លា។

បាបមួយនៃបាបទាំង៧របស់មហាត្មៈគន្ធីដែល
នាំឱ្យប្រទេសអន្តរាយគឺសាសនាគ្មាន
ការលះបង់។

ព្រះពុទ្ធនៃយើងមិនមែននាំមនុស្សលោកឱ្យ
ជឿទេ ប៉ុន្តែនាំឱ្យមនុស្សគិត ត្រិះរិះ និង
ពិសោធន៍ គឺនាំឱ្យមនុស្សមានសទ្ធា។

មានទឹកចិត្តស្មោះត្រង់ ទស្សនវិស័យភ្លឺថ្លា
សេចក្ដីប្ដេជ្ញាចិត្តខ្ពង់ខ្ពស់ អ្នកអាច
ធ្វើនយោបាយបានហើយ។

សកម្មភាពតាមកាយ និងវាចារ ហៅថាសុជីវធម៌
សកម្មភាពតាមមនោ ហៅថាសីលធម៌។

យើងគោរពមនុស្សគឺគោរពសន្ដានចិត្ត ឬ
ដួងចិត្តដែលប្រកបទៅដោយមេត្តា និង
ករុណារបស់មនុស្សនោះ។

អ៊ីស្រាអែលជា
ពលរដ្ឋមានបញ្ញា ពលមានការ
ប្ដេជ្ញាខ្ពស់ និងសាមគ្គីជាតិ។ នេះគឺជា
កម្លាំងស្នូលក្នុងការការពារ និងកសាងជាតិ
សំខាន់បំផុត។

រដ្ឋបាល
ខ្លី សាមញ្ញ ងាយ ថ្លា
របស់សិង្ហបុរីធ្វើឲ្យពិភពលោក
ទទួលស្គាល់ និងសើ្ញចសរសើរ ព្រោះ
ជាប្រព័ន្ធរដ្ឋបាលភ្លឺស្វាង និងនាំប្រទេស
ដល់គោលដៅសុភមង្គលដោយមានភាពសុចរិត
តម្លាភាព និងដើម្បីប្រយោជន៍រួម។

លីក្វានយូ (Lee Quan Yew) ជាជនផ្ដាច់ការ
ភ្លឺស្វាងដែលមនុស្សលើពិភពលោកទទួល
ស្គាល់ ៖ ពលត្រូវមានវិន័យ សេចក្ដីថ្លៃថ្នូរ
(ក្បាល ៖ ត្រូវមានបញ្ញាឆ្លាតវៀងវៃ
បេះដូង ៖ ត្រូវមានបេះដូងដ៏ស្មោះត្រង់
កណ្ដាប់ដៃ ៖ ត្រូវមានសេចក្ដីប្ដេជ្ញាចិត្ត
និងឆន្ទៈមុះមុត)។

យន្តការ៨ចំណុច
របស់យើងធ្វើឲ្យសិទ្ធិ និងអំណាច
ក្នុងការចាត់ចែងកិច្ចការប្រទេសជាតិស្ថិតក្នុង
កណ្ដាប់ដៃប្រជាពលរដ្ឋ
ជាអចិន្ត្រៃយ៍។






www.camldp.org